ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

# សេចក្តីថ្លែងការណ៍ព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង
# ខែមករា ឆ្នាំ២០០៩

អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការធានាថា សាធារណជនមានការយល់ដឹងច្បាស់អំពីដំណាក់កាលដំបូងនៃការជំនុំជម្រះប្រឆាំងនឹង **កាំង ហ្គេចអ៊ាវ** ហៅ **"ឌុច"**។

ការជំនុំជម្រះចាប់ផ្តើមដោយមានសវនាការបឋម បន្ទាប់មកគឺសវនាការលើអង្គសេចក្តី ដែលមិនទាន់បានកំណត់កាលបរិច្ឆេទនៅឡើយ។

១. **សវនាការបឋម** ត្រូវបានកំណត់ពេលចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ និងប៉ុន្មានថ្ងៃបន្តបន្ទាប់ទៅតាមភាពចាំបាច់ ដែលនឹងពិចារណាលើពាក្យសុំឲ្យទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី និងវិធានការការពារដែលពួកគេបានស្នើសុំ។ សវនាការនេះក៏នឹងពិចារណាលើបញ្ហាផ្លូវច្បាប់ និងបញ្ហានីតិវិធីបឋម ដែលអាចមានឥទ្ធិពលទៅលើដំណើរការនៃការជំនុំជម្រះលើអង្គសេចក្តី ហើយនឹងកំណត់ជាចុងក្រោយទៅលើការកំណត់ពេលកោះហៅសាក្សី និងអ្នកជំនាញឲ្យមកដល់សក្ខីកម្មនៅពេលជំនុំជម្រះ។ ជនជាប់ចោទ សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនបញ្ចេញយោបល់នៅឯសវនាការបឋម ទៅលើបញ្ហានៃអង្គសេចក្តីទេ។

បន្ទាប់ពីសវនាការបឋមបញ្ចប់ទៅ ប្រធានអង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទទៅលើសវនាការលើអង្គសេចក្តី បន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គជំនុំជម្រះសាលាដំបូង។



Original EN: 01699268-01699268

២.　**សវនាការលើអង្គសេចក្តី** នឹងពិចារណាទៅលើភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង។ ជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់សក្ខីកម្ម ឬធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ក្នុងដំណាក់កាលនេះនៃការជំនុំជម្រះ។

**យើងសូមរម្លឹកថា ចំពោះអ្នកដែលកំពុងដាក់ពាក្យសុំឲ្យទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ពួកគេត្រូវដាក់ត្រឹមថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៦:០០ ជាកំហិត។**